**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិមកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** ត្រូវបានបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- នាយឧត្តមសេនីយ៍ | ទៀ បាញ់ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | ជាប្រធាន |
| ២- នាយឧត្តមសេនីយ៍ | ប៉ុល សារឿន | អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | ជាអនុប្រធាន |
| ៣- នាយឧត្តមសេនីយ៍ | មាស សុខសុន | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាអនុប្រធាន |
| ៤- ឯកឧត្តម | អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៥- នាយឧត្តមសេនីយ៍ | គន់ គីម | អគ្គមេបញ្ជាការរងនិងជានាយសេនាធិការចំរុះ | ជាអនុប្រធាន |
| ៦- នាយឧត្តមសេនីយ៍ | មឿង សំផន | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ៧- នាយឧត្តមសេនីយ៍ | នាង ផាត | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ៨- ឧត្តមសេនីយ៍ឯក | ជាន់ ឌួន | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ៩- ឧត្តមសេនីយ៍ឯក | ឯម ម៉ាន់សាវ៉ាត | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ១០- ឧត្តមសេនីយ៍ឯក | ស៊ុន ឈឿន | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ១១- នាយឧត្តមសេនីយ៍ | មាស សុផា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ ក.ជ.គ | ជាសមាជិក |
| ១២- ឧត្តមសេនីយ៍ឯក | នួន ស៊ីផាន | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ១៣- ឧត្តមសេនីយ៍ឯក | ស៍ ចន្ទសុខន | អគ្គលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ១៤- ឧត្តមសេនីយ៍ឯក | ចៅ ភិរុណ | អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | ជាសមាជិក |
| ១៥- ឧត្តមសេនីយ៍ឯក | ស៊ុំ សំណាង | អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ | ជាសមាជិក |
| ១៦- ឧត្តមសេនីយ៍ឯក | មាស សាមិន | អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា | ជាសមាជិក |
| ១៧- ឧត្តមសេនីយ៍ឯក | ឈឹម សុចន្ធី | អគ្គនាយក អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស | ជាសមាជិក |
| ១៨- ឧត្តមសេនីយ៍ឯក | មាល់ ធឿម | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | ជាសមាជិក |
| ១៩- ឧត្តមសេនីយ៍ឯក | ជា តារា | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | ជាសមាជិក |
| ២០- ឧត្តមសេនីយ៍ឯក | ហ៊ឹង ប៊ុនហៀង | អគ្គមេបញ្ជាការរងនិងនាយករងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | ជាសមាជិក |
| ២១- ឧត្តមសេនីយ៍ឯក | សៅ សុខា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថ | ជាសមាជិក |
| ២២- ឧត្តមនាវីឯក | អ៊ុខ សំទាន់ | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | ជាសមាជិក |
| ២៣- ឧត្តមសេនីយ៍ឯក | ញឹក ឈុន | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | ជាសមាជិក |
| ២៤- ឧត្តមសេនីយ៍ឯក | ឡុង ឫទ្ធីយ៉ា | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | ជាសមាជិក |
| ២៥- ឧត្តមសេនីយ៍ឯក | ជា សារិន | មេបញ្ជាការរងនិងជានាយសេនាធិការកងទ័ពជើងគោក | ជាសមាជិក |
| ២៦- ឧត្តមសេនីយ៍ឯក | សឹម សំណាង | មេបញ្ជាការកងទ័ពជើងអាកាស | ជាសមាជិក |
| ២៧- ឧត្តមនាវីឯក | ទៀ វិញ | មេបញ្ជាការកងទ័ពជើងទឹក | ជាសមាជិក |
| ២៨- ឧត្តមសេនីយ៍ឯក | មាស សិរុយ | នាយក នាយកដ្ឋានបុគ្គលិក | ជាសមាជិក |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ២៩- ឧត្តមសេនីយ៍ឯក | ជាំ ឫទ្ធី | នាយកទីចាត់ការបុគ្គលិក | ជាសមាជិក |
| ៣០- ឧត្តមសេនីយ៍ឯក | ឥត សារ៉ាត់ | នាយកទីចាត់ការហិរញ្ញវត្ថុ | ជាសមាជិក |

**មាត្រា២** : ក្រុមប្រឹក្សាកែទម្រង់កងយោធពលខេមរភូមិន្ទមានភារកិច្ចដូចខាងក្រោម :

-ធ្វើផែនការកំណែទម្រង់និងផែនការកសាងកំលាំងយូរអង្វែងដែលទាក់ទងទៅនឹងកំណែទម្រង់កងយោធពលខេមរភូមិន្ទ តាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

-តាមដានត្រួតពិនិត្យជាអចិន្ត្រៃយ៍នូវកម្មវិធីកំណែទម្រង់ ។

-សរុបលទ្ធផលការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

-ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទមានសិទ្ធិបង្កើតគណៈកម្មការជំនាញទៅតាមសភាពការណ៍ចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា៣** : ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានទទួលបន្ទុកការងារអចិន្ត្រៃយ៍ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយ៍ឯក | នួន ស៊ីផាន | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | ជាអគ្គលេខាធិការ |
| ២- ឧត្តមសេនីយ៍ឯក | មាស សំអូល | នាយក នាយកដ្ឋានបុគ្គលិក | ជាអគ្គលេខាធិការរង |
| ៣- ឧត្តមសេនីយ៍ទោ | ខៅ សាខន | អគ្គលេខាធិការរង ក្រសួងការពារជាតិ | ជាអគ្គលេខាធិការរង |
| ៤- ឧត្តមសេនីយ៍ទោ | ជឹម សុខ | នាយករងទីចាត់ការបុគ្គលិក | ជាអគ្គលេខាធិការរង |
| ៤- ឧត្តមសេនីយ៍ទោ | ជួប សំបូរ | នាយករងនាយកដ្ឋានបុគ្គលិក | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥- ឧត្តមសេនីយ៍ទោ | ឈឿម រតនា | នាយករងទីចាត់ការបុគ្គលិក | ជាសមាជិកអចិន្ត្រៃយ៍ |
| ៦- ឧត្តមសេនីយ៍ទោ | ទ័ាន ឫទ្ធី | នាយករងទីចាត់ការហិរញ្ញវត្ថុអគ្គបញ្ជាការ | ជាសមាជិក |
| ៧- ឧត្តមសេនីយ៍ទោ | អ៊ួន ឈន | នាយរងសេនាធិការ និងជានាយការិយាល័យទី១ ក ជ គ | ជាសមាជិក |
| ៨- ឧត្តមសេនីយ៍ត្រី | ញឹម សុវណ្ណ | នាយរងសេនាធិការ និងជានាយការិយាល័យទី១ ក ជ អ | ជាសមាជិក |
| ៩- ឧត្តមនាវីត្រី | អ៊ុំ ម៉ុនលី | នាយរងសេនាធិការ និងជានាយការិយាល័យទី១ ក ជ ទ | ជាសមាជិក |
| ១០- ឧត្តមសេនីយ៍ត្រី | ស្រ៊ុន គឹមស្រេង | នាយរងសេនាធិការ និងជានាយការិ.ទី១ អ.ហ | ជាសមាជិក |

**មាត្រា៤** : អគ្គលេខាធិការដ្ឋានទទួលបន្ទុកធ្វើជាសេនាធិការផ្ទាល់ របស់ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ហើយមានភារកិច្ចដូចខាងក្រោម :

- ស្រាវជ្រាវពិចារណា និងលើកយោបល់ស្តីពីការកែទម្រង់ជូនក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ។
- ត្រួតពិនិត្យផែនការ និងជំរុញការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទ ។
- ណែនាំ ដំណើរការកម្មវិធីការងាររបស់គណៈកម្មការកំណែទម្រង់ ធានាឱ្យដំណើរការតាមផែនការកំណត់ ដោះស្រាយរាល់សំណើរបស់គណៈកម្មការដែលជួបការលំបាក ។
- ធ្វើការងារមួយចំនួនទៀតដែលប្រធានក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទប្រគល់ឱ្យ ។

**មាត្រា៥** : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា៦** ៖ រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពក្នុងមាត្រា១ មាត្រា៣ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់**
-ដូចមាត្រា ១.៣.៦
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com